ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# វិធានការទប់ស្កាត់ និងការពារការផ្ទុះឡើងនូវជំងឺគ្រុនឈាម នឹងរួមគ្នាប្រយុទ្ធនឹងជំងឺគ្រុនឈាម

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណជន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់មេត្តាជ្រាបថា ស្ថានភាពជំងឺគ្រុនឈាមក្នុងកំឡុងឆ្នាំ២០១៩នេះ មានការកើនឡើងគួរឲ្យកត់សម្គាល់ ច្រើនជាងឆ្នាំ២០១៨កន្លងទៅ។ គ្រុនឈាមជាជំងឺរបស់មនុស្សគ្រប់វ័យ ដែលបង្កឡើងដោយសត្វមូសខ្លាញីខាំបឺតឈាមចម្លងមេរោគគ្រុនឈាម ពីមនុស្សម្នាក់ទៅម្នាក់ទៀត។ សត្វមូសខ្លាកកើតកូនចៅនៅក្នុងទឹកថ្លាស្អាត និងចូលចិត្តរស់នៅជិតមនុស្ស ហើយហើរក្នុងចំងាយមិនលើសពី១៥០ម៉ែត្រពីទីកន្លែងកកើត។

យោងតាមការស្រាវជ្រាវបាណកសាស្ត្ររបស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ (មគច) រួមសហការជាមួយមន្ទីរសុខាភិបាលរាជធានី-ខេត្ត បានបញ្ជាក់ឲ្យឃើញថា សត្វមូសខ្លាចូលចិត្តពងបង្កបង្កើតកូនចៅ នៅក្នុងសំបកកង់ឡាន និងសំបកកង់ម៉ូតូចាស់ៗ ១១ដង ច្រើនជាង វត្ថុដាក់ទឹកសំរាប់ប្រើប្រាស់ផ្សេងៗ។ ជំងឺគ្រុនឈាម មានទំនាក់ទំនងយ៉ាងខ្លាំងជាមួយនឹងកត្តាអាកាសធាតុ យោងតាមការសិក្សារបស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រក្នុងឆ្នាំ២០១៨ កន្លងមកនេះ បានបញ្ជាក់ថា ជំងឺគ្រុនឈាមក្នុងរដូវវស្សាកើនឡើងចំនួនជាង២ដង នៃចំនួនក្នុងរដូវប្រាំងកំដៅកើនឡើងមួយដឺក្រេស្មើនិងជំងឺគ្រុនឈាមកើន៣០% ចំនួនទឹកភ្លៀងកើនមួយមីលីមែត្រស្មើនិងកំណើនជំងឺគ្រុនឈាម ១១% និងកំណើនថ្ងៃមានធ្លាក់ភ្លៀងមួយថ្ងៃ ស្មើនិងកំណើនជំងឺគ្រុនឈាម ៨%។

ដើម្បីការពារសុខភាពជៀសផុតពីការឆ្លងជំងឺគ្រុនឈាម ដោយសារសត្វមូសខ្លាញីខាំ និងការខាំរបស់សត្វមូស ពិសេសដើម្បីបង្ការការឈឺនិងស្លាប់ ដោយសារជំងឺគ្រុនឈាមឲ្យកាន់តែមានប្រសិទ្ធភាពនោះ **ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល សូមអំពាវនាវដល់ប្រជាពលរដ្ឋគ្រប់រូប និងអាជ្ញាធរមូលដ្ឋាន ត្រូវចូលរួមចលនាកាត់បន្ថយ និងទប់ស្កាត់ការកកើតសត្វមូស ដោយប្រកាន់ខ្ជាប់នូវគោលជំហរជាប្រជាជនគំរូមួយរូប គឺ "*ខ្ញុំ និងគ្រួសារខ្ញុំ ជាគ្រួសារគំរូ ព្រោះផ្ទះខ្ញុំ និងលំនៅដ្ឋានរបស់ខ្ញុំ គ្មានដង្កូវទឹក*" តាមរយៈការអនុវត្តន៍នូវវិធានការដូចខាងក្រោម៖

**វិធានការទី១ ៖** អាណាព្យាបាល មាតាបិតា កុមារាកុមារី គ្រប់រូប រួមទាំងអាជ្ញាធរមូលដ្ឋាន ត្រូវសកម្ម ចូលរួមកំចាត់ដង្កូវទឹកនៅតាមទីកន្លែងដែលមានទឹកដក់ ដូចជា ពាង អាងទឹក ថូផ្កា ចានទ្រជើងតុទូ ក្រឡ ធុង ខាប់ ជាដើម ដោយការផ្លាស់ប្តូរទឹក និងលាងសំអាតជាប្រចាំឲ្យបានយ៉ាងតិចមួយដង ក្នុងមួយអាទិត្យ ឬត្រូវគ្របគំរបឲ្យបានជិតល្អ និងត្រូវសហការជាមួយបណ្តាញសុខាភិបាលនៅតាមមូលដ្ឋាន ដើម្បីដាក់ថ្នាំអាបែតសម្លាប់ដង្កូវទឹក នៅក្នុងអាង ឬពាងទឹក ឬកន្លែងដែលស្តុកទឹក ឬចិញ្ចឹមកូនត្រីប្រាំពីរពណ៌នៅកន្លែងដែលអាចចិញ្ចឹមបាន។ ចំពោះសម្ភារៈដក់ទឹកផ្សេងទៀត ដែលមិនប្រើប្រាស់ទុកចោល ដូចជាសំបកកង់ឡាន-ម៉ូតូ សំបកដប កំប៉ុង ត្រឡោកដូង ចានបាយសម្លជ័រ កំប៉ុងជ័រកាហ្វេ និងវត្ថុដក់ទឹកផ្សេងទៀត ត្រូវកប់ ឬដុត ឬកំទេចចោល ឬទុកដាក់ឲ្យមានរបៀប កុំឲ្យមានទឹកដក់។

**វិធានការទី២ ៖** សូមឲ្យម្ចាស់ការដ្ឋានសំណង់ រួមទាំងកម្មករ និងកម្មការនីទាំងអស់ ដែលកំពុងបំពេញការងារនៅតាមការដ្ឋានសំណង់ទាំងអស់ ត្រូវធ្វើអនាម័យបរិស្ថាន ឲ្យបានស្អាតនៅក្នុងបរិវេណការដ្ឋានសំណង់របស់ខ្លួន ជាពិសេសត្រូវលុបបំបាត់វត្ថុនិងថ្លុកដក់ទឹក រៀបចំទុកដាក់សម្ភារៈសំណង់ដែលអាចដក់ទឹកនៅក្នុងទីកន្លែងដែលមានដំបូលត្រឹមត្រូវ ដើម្បីការពារកុំអោយដក់ទឹក លុបបំបាត់ប្រភព និងជម្រកមូសខ្លាដែលជាភ្នាក់ងារចម្លងជំងឺគ្រុនឈាម ហើយអាចរាតត្បាតដល់ប្រជាជនទាំងអស់ ដែលរស់នៅចម្ងាយ១៥០ម៉ែត្រជុំវិញការដ្ឋានសំណង់នោះ។ ទន្ទឹមគ្នានេះដែរ មន្ទីរសុខាភិបាលរាជធានី-ខេត្តទាំង២៥ ត្រូវសហការជាមួយអាជ្ញាពាក់ព័ន្ធ ដើម្បីចុះត្រួតពិនិត្យនៅតាមការដ្ឋានសំណង់ ជំរុញអនុវត្តការងារនេះឲ្យមានប្រសិទ្ធភាព ដើម្បីចូលរួមកាត់បន្ថយអត្រាឈឺ និងស្លាប់ដោយសារជំងឺគ្រុនឈាម។

**វិធានការទី៣ ៖** អាជីវករ និងម្ចាស់អាជីវកម្មទាំងឡាយ ដែលប្រកបរបរពាក់ព័ន្ធនឹងសំបុកកង់ឡាន-ម៉ូតូ "*សូមធ្វើការគ្រប់គ្រងសំបកកង់ទាំងនោះ ឲ្យមានសុវត្ថិភាព ជៀសផុតពីការដក់ទឹក*" ដោយមិនត្រូវទុកចោលពាសវាលពាសកាល បង្កើតបានជាប្រភពកកើត និងជំរកមូសខ្លាដ៏គ្រោះថ្នាក់បំផុត ដែលអំណោយផលដល់ការចម្លងជំងឺគ្រុនឈាមកើនឡើង និងអាចឈានទៅរកការរាតត្បាតគ្រប់ពេលវេលា។ វិធីសាស្ត្រក្នុងការគ្រប់គ្រងសំបកកង់ ដោយសុវត្ថិភាពគ្មានសត្វមូសកកើត គឺត្រូវ៖ *ដាក់គរត្រួតលើគ្នា គ្របដោយបន្ទះក្តារជិត ឬស្បៃមុង ចាក់ប្រេងម៉ាស៊ីនដែលខូចឈប់ប្រើប្រាស់ចូល ឬចាក់ដីបំពេញ ជាពិសេសដាក់នៅក្រោមដំបូល* ដើម្បីការពារកុំឲ្យមានដក់ទឹក ដែលបង្កទៅជាប្រភពកកើត និងជាជំរកមូសខ្លា។

**វិធានការទី៤ ៖** ត្រូវប្រកាន់ខ្ជាប់នូវទំលាប់រស់នៅស្អាត មានអនាម័យផ្ទះសំបែង ផ្ទះមានពន្លឺចេញចូល ទុកដាក់របស់របរ-សំលៀកបំពាក់ក្នុងក្រៅផ្ទះមានសណ្តាប់ធ្នាប់ លុបបំបាត់ព្រៃស៊ប់ទ្រុបជុំវិញផ្ទះ ដើម្បីកាត់បន្ថយជំរកសត្វមូសមកតោងជ្រកទុំជិតខ្លួនយើង ដែលងាយនឹងខាំយើង។ អំឡុងពេលថ្ងៃ គឺចាំបាច់ត្រូវប្រើប្រាស់សំលៀកបំពាក់មានដៃវែងជើងវែង និងសម្រាន្តក្នុងមុងជាប្រចាំ ទាំងថ្ងៃ ទាំងយប់។ មិនត្រូវអង្គុយលេងនៅជិតទីកន្លែងងងឹតៗនោះទេ។

**វិធានការទី៥ ៖** ករណីមានរោគសញ្ញាក្ដៅខ្លួនខ្លាំងភ្លាមៗ ត្រូវប្រញ៉ាប់នាំអ្នកជំងឺទៅរកសេវាពិនិត្យ និងព្យាបាល របស់រដ្ឋ (សេវាសាធារណៈ) ដូចជាមណ្ឌលសុខភាព និងមន្ទីរពេទ្យ ដែលនៅជិតបំផុតជាបន្ទាន់ (មិនឲ្យយឺតជាង៧២ម៉ោង បន្ទាប់ពីក្ដៅខ្លួន) ហើយ ***សូមកុំសាកល្បងព្យាបាលអ្នកជំងឺគ្រុនក្ដៅខ្លាំងភ្លាមៗនេះដោយខ្លួនឯង ឬពន្យារពេលតាមដានព្យាបាលជំងឺក្នុងសេវាឯកជនដែលគ្មានសមត្ថភាពផ្នែកជំងឺគ្រុនឈាមនេះឲ្យសោះ*** ។ ជំងឺគ្រុនឈាម **អាចនឹងសម្លាប់អ្នកជំងឺបានគ្រប់ពេល** ប្រសិនបើមិនបានទៅទទួលការព្យាបាលនៅសេវារដ្ឋដែលមានការបណ្ដុះបណ្ដាលត្រឹមត្រូវ ឲ្យបានទាន់ពេលវេលា ឬក៏សាកល្បងព្យាបាលនៅសេវាឯកជន ដែលមិនមានចំណេះជំនាញខាងជំងឺគ្រុនឈាម ឬបើមានការប្រើប្រាស់ប្រភេទថ្នាំអាស្ពីរីន។

**វិធានការទី៦ ៖** គ្រប់មន្ទីរសុខាភិបាលរាជធានី-ខេត្តទាំង២៥ ត្រូវបន្តផ្ដល់ការបណ្ដុះបណ្ដាលដល់គ្រូពេទ្យព្យាបាលទាំងសេវារដ្ឋ និងសេវាឯកជន អំពីរបៀបធ្វើរោគវិនិច្ឆ័យ-ព្យាបាល-ថែទាំអ្នកជំងឺគ្រុនឈាមមុន និងអំឡុងរដូវភ្លៀង។ សម្រាប់សេវាឯកជន ដែលមិនមានចំណេះជំនាញ សម្ភារៈ និងឧបករណ៍ត្រឹមត្រូវសម្រាប់ធ្វើរោគវិនិច្ឆ័យ-ព្យាបាល-ថែទាំជំងឺគ្រុនឈាម គឺក្រសួងសុខាភិបាលមិនអនុញ្ញាតឲ្យទទួលការព្យាបាលជំងឺគ្រុនឈាមនេះឡើយ ហើយត្រូវតែបញ្ជូនជាបន្ទាន់មកមន្ទីរពេទ្យរដ្ឋ ដែលនៅជិតបំផុត។

**វិធានការទី៧ ៖** គ្រប់មន្ទីរសុខាភិបាលរាជធានី-ខេត្តទាំង២៥ ត្រូវចាត់ចែងការផ្ដល់សេវា និងកន្លែងសម្រាកព្យាបាលជំងឺគ្រុនឈាមនៅក្នុងមន្ទីរពេទ្យឲ្យបានល្អ និងត្រូវបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យផ្សេងទៀតក្នុងករណី ដែលមានករណីជំងឺគ្រុនឈាមច្រើនហួសសមត្ថភាពនៅក្នុងមន្ទីរពេទ្យណាមួយ ដោយមិនទុកឲ្យមានការយឺតយ៉ាវក្នុងការទទួលបាននូវសេវាពិនិត្យ និងព្យាបាលឡើយ។

**វិធានការទី៨ ៖** គ្រប់មន្ទីរសុខាភិបាលរាជធានី-ខេត្តទាំង២៥ ត្រូវរៀបចំប្រជុំជាបន្ទាន់ និងធ្វើការប្រជុំជារៀងរាល់ពីរអាទិត្យម្ដង ជាមួយផ្នែកពាក់ពន្ធ័ទាំងអស់ និងអង្គការដៃគូអភិវឌ្ឍន៍នៅក្នុងសមត្ថកិច្ចរបស់ខ្លួន ដើម្បីពិនិត្យ និងដាក់ចេញនូវវិធានការនានា ព្រមទាំងជម្រុញផ្សព្វផ្សាយសារអប់រំសុខភាពទប់ស្កាត់ការរាតត្បាតជំងឺគ្រុនឈាម និងចលនាឲ្យមានការគាំទ្រ ចូលរួមយ៉ាងសកម្ម និងទូលំទូលាយក្នុងការប្រយុទ្ធនឹងជំងឺគ្រុនឈាមឲ្យកាន់តែខ្លាំងក្លាបន្ថែមទៀត បើទោះជាបច្ចុប្បន្ននេះប្រទេសកម្ពុជា នៅមានករណីជំងឺតិចនៅឡើយក៏ដោយ បើប្រៀបធៀបទៅនឹងប្រទេសក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ដែលកំពុងរាតត្បាតយ៉ាងខ្លាំង។

ក្រសួងសុខាភិបាល សូមអំពាវនាវដល់អាជ្ញាធរមូលដ្ឋាន ក្រសួង មន្ទីរ ឬអង្គភាពពាក់ព័ន្ធ អង្គការសុខភាពពិភពលោក អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ជាតិ និងអន្តរជាតិទាំងអស់ បន្តចូលរួមជួយអន្តរាគមន៍ និងសហការពេញលេញ ព្រមទាំងបន្តជួយឧបត្ថម្ភគាំទ្រ ក្នុងកិច្ចសហការចូលរួមជាមួយកម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្ររបស់ក្រសួងសុខាភិបាល ក៏ដូចជាជួយដល់មន្ទីរសុខាភិបាលរាជធានី-ខេត្ត ដើម្បីទប់ស្កាត់ការចម្លងជំងឺគ្រុនឈាមនៅតាមសហគមន៍ ឲ្យកាន់តែមានប្រសិទ្ធិភាពខ្ពស់ ដើម្បីចៀសផុតពីជំងឺគ្រុនឈាមដែលអាចនឹងផ្ទុះឡើងបានគ្រប់ពេលនេះផងដែរ។

**ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះប្រជាពលរដ្ឋទាំងអស់ និងអាជ្ញាធរមូលដ្ឋាន ព្រមទាំងភាគីពាក់ព័ន្ធទាំងអស់ ដែលបានយកចិត្តទុកដាក់ អនុវត្តតាមការណែនាំខាងលើ និងសូមប្រសិទ្ធពរជ័យ ជូនដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឲ្យទទួលបាននូវ សុខភាពល្អទាំងអស់គ្នា ចៀសផុតនូវការចម្លងជំងឺគ្រុនឈាម ។

ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖
លោកវេជ្ជបណ្ឌិត **លាង ឫទ្ធា** លេខទូរស័ព្ទ ០១២ ៧១៥ ៦៦៦
និងអ៊ីម៉ែល rithealeang@gmail.com

ថ្ងៃព្រហស្បតិ៍ ១១កើត ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១៩

## វិធីសាស្ត្រក្នុងការគ្រប់គ្រងសំបកកង់ដោយសុវត្ថិភាពគ្មានសត្វមូសកកើត











## ចូរកុំទុកចោលសំបកកង់ពាសវាល ពាសកាល







យើងនាំគ្នាបំបាត់ជម្រកមូសខ្លា

ទឹកភ្លៀងដក់ក្នុងសំបកកង់ឡាន ម៉ូតូ ជាជម្រកមូសខ្លា



លាងពាងយ៉ាងហោចណាស់អោយបានម្តងក្នុង១សប្តាហ៍



ដាក់ត្រីប្រាំពីរពណ៌អោយស៊ីដង្កូវទឹក